ភ្នំពេញ , ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៩៣

# អនុក្រឹត្យលេខ ០៦ អនក្រ ស្តីពីការ
# ផ្ទេរសមត្ថកិច្ចចេញលិខិតឆ្លងដែនប្រជាពលរដ្ឋ
# មកក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

* * *

- យោងតាមព្រះរាជក្រឹត្យ របស់សម្តេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះប្រមុខរដ្ឋនៃកម្ពុជា ចុះថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៣
- យោងតាមសេចក្តីស្នើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ លេខ ៣២៧១ កស .ការទ ចុះថ្ងៃទី ៦ ខែ សីហា ឆ្នាំ ១៩៩៣
- យោងតាមការឯកភាពរបស់ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ លេខ ០២៦ ហស. មផ.សជ ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៣

## សំរេច

មាត្រា ១ : ផ្ទេរសមត្ថកិច្ច ចេញលិខិតឆ្លងដែនប្រជាពលរដ្ឋពី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ មកក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ។

មាត្រា ២ : បទបញ្ញត្តិទាំងអស់ពីមុនដែលផ្ទុយ និង អនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ និង សន្តិសុខជាតិ ត្រូវទទួលភារកិច្ចចាត់ការអោយបានសំរេចតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខានេះតទៅ ។

**សហប្រធាន**

រដ្ឋាភិបាលជាតិបណ្តោះអាសន្ននៃកម្ពុជា

ព្រះហស្តលេខា និង ត្រា | ហត្ថលេខា និង ត្រា

ស្តេចក្រុមហ្លួង **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន**

www.pheakdeylaw.com